ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ................ អនក្រ

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់អំណាច និងតួនាទីរបស់មន្ត្រីដែលត្រូវបានចាត់តាំងដើម្បីត្រួតពិនិត្យ ធ្វើអធិការកិច្ច និងរាយការណ៍ពីសកម្មភាពការងារស្វែងរុករក ជីកយករ៉ែ ស្រាវជ្រាវ ការវិភាគពាក់ព័ន្ធនឹងរបៀបរបបគ្រប់គ្រង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/................ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សំរេច

**មាត្រា ១.-**

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចាត់តាំងមន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ ដើម្បីត្រួតពិនិត្យ ធ្វើអធិការកិច្ច និងរាយការណ៍ពីសកម្មភាពការងារស្វែងរុករក ជីកយករ៉ែ ស្រាវជ្រាវ ការវិភាគពាក់ព័ន្ធនឹងរបៀបរបបគ្រប់គ្រងឱ្យមានប្រសិទ្ធិភាពខ្ពស់។

**មាត្រា ២.-**

មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ ដែលត្រូវបានចាត់តាំង មានតួនាទីជា អធិការកិច្ចរ៉ែ ។

**មាត្រា ៣.-**

មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ ដែលត្រូវបានចាត់តាំង មានភារកិច្ចដូចតទៅ :

១- ទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ លើរបៀបរបបគ្រប់គ្រងស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

២- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពជាប្រចាំលើការងារស្វែងរុករក និងជីកយករ៉ែតាមឆ្នាំបន្តបន្ទាប់ ហើយដាក់របាយការណ៍នោះជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ

៣-ប្រមូលផ្តុំពត៌មាន និងរក្សាទុកឯកសារប្រតិបត្តិការស្វែងរុករក ជីកយករ៉ែ ការដឹកជញ្ជូន ប្រព្រឹត្តិកម្ម ការរកទីផ្សារ និងការនាំចេញធនធាន និង ផលិតផលរ៉ែ

៤- ធ្វើការតាមដាន និងពិនិត្យ ដើម្បីបញ្ជាក់ពីការអនុវត្តបទប្បញ្ញត្តិទាំងអស់ នៃច្បាប់នេះ

៥- ត្រួតពិនិត្យការអនុវត្តបទបញ្ជា ឱ្យបានត្រឹមត្រូវលើសុខភាព និងសុវត្ថិភាព របស់ពលករ និងសាធារណជនទូទៅ និងការពារបរិស្ថាន

៦- ទទួលតួនាទីផ្សេងៗទៀត តាមការកំណត់របស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

**មាត្រា ៤.-**

អំណាចនៃមន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ ដែលត្រូវបានចាត់តាំង ត្រូវបានកំណត់ដូចខាងក្រោម :

- មានសិទ្ធចុះធ្វើអធិការកិច្ចបានគ្រប់ពេលវេលា លើរាល់សកម្មភាពស្វែងរុករក និង/ឬអាជីវកម្មធនធានរ៉ែ ឬកែច្នៃធនធានរ៉ែទាំងអស់ដែលស្ថិតនៅក្នុងតំបន់មានអាជ្ញាប័ណ្ណធនធនរ៉ែ និងតំបន់ផ្សេងទៀតដែលមិនស្ថិតនៅក្រោមអាជ្ញាប័ណ្ណធនធានរ៉ែ ។
- មានសិទ្ធិយកឧបករណ៍ និងសម្ភារៈបច្ចេកទេសចាំបាច់ នៅពេលចុះទៅធ្វើអធិការកិច្ចនៅក្នុងតំបន់មាន អាជ្ញាប័ណ្ណធនធានរ៉ែ ឬគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ
- មានសិទ្ធិស៊ើបអង្កេតលើរបាយការណ៍ ឬលទ្ធផលទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការស្វែងរុករក និង/ឬអាជីវកម្មធនធានរ៉ែ ឬកែឆ្នៃធនធានរ៉ែ ការស្តារការដ្ឋាន ជីកយករ៉ែឡើងវិញ ការការពារ បរិស្ថាន ការវាយតម្លៃបរិមាណផលិតផលធនធានរ៉ែដែលជីកយកបាន ការបង់សួយសារលើតម្លៃ ធនធានរ៉ែ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត ។
- ត្រួតពិនិត្យ និងស៊ើបអង្កេតរាល់ការបំពានច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

**មាត្រា ៥.-**

មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ ដែលត្រូវបានចាត់តាំង ត្រូវធ្វើរាយការណ៍ពីសកម្មភាពការងារស្វែងរុករក ជីកយករ៉ែ ស្រាវជ្រាវ ការវិភាគពាក់ព័ន្ធនឹងរបៀបរបបគ្រប់គ្រង ជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បី ពិនិត្យ និងសំរេច ក្នុងកំឡុងពេលយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃ បន្ទាប់ពីបានបញ្ចប់ការធ្វើអធិការកិច្ចមួយលើកៗ ។

**មាត្រា ៦.-**

ការចុះបំពេញភារកិច្ច មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ ដែលត្រូវបានចាត់តាំង ត្រូវមានឯកសណ្ឋានសំគាល់ជាអធិការកិច្ចរ៉ែ ដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយនេះ ។

**មាត្រា ៧.-**

នៅពេលចុះបំពេញភារកិច្ចនៅការដ្ឋានស្វែងរុករក និង/ឬអាជីវកម្មធនធានរ៉ែ មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ ដែលត្រូវបានចាត់តាំង ត្រូវមានអត្តសញ្ញាណប័ណ្ណសំគាល់ខ្លួន និងលិខិតបញ្ជាបេសកកម្មដែលចេញដោយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

**សម្តេចនាយករដ្ឋមន្ត្រី**

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**កន្លែងទទួល :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ